# ព្រះរាជក្រម

នស/រកម/១២១៥/០១៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៣/នស/៩៤/ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋបេឡារុស ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋ បេឡារុសស្តីពីការជំរុញ និងការការពារទៅវិញទៅមក នៃវិនិយោគ

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ ដែលបានចុះហត្ថលេខានៅទីក្រុងមីនស្ក នៃសាធារណរដ្ឋបេឡារុស នាថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៥

នស/រកម.១២១៥.០១២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ហត្ថលេខា**

**គាត ឈន់**

លេខ: ១១៧២ ស.ណ

**សំណៅដែលមានឥឡូវជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៧៧.សណស.ហបក

# សេចក្តីថ្លែងហេតុ
# នៃសេចក្តីព្រាងច្បាប់
# ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ

កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគនេះ ត្រូវបានចុះហត្ថលេខានៅទីក្រុងមីនស្ក នៃសាធារណរដ្ឋបេឡារុសកាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ ដោយ ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាតំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម វ៉ាលានស៊ីន វីបាគូ អនុរដ្ឋមន្ត្រីក្រសួងការបរទេស ជាតំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស។

កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមាននៅកាលបរិច្ឆេទចុងក្រោយដែលភាគីជាប់កិច្ចសន្យាបានជូនដំណឹងតាមផ្លូវទូតពីការបានបំពេញរួចរាល់នូវនីតិវិធីផ្ទៃក្នុងរបស់ខ្លួន ហើយមានសុពលភាពអនុវត្តរយៈពេល ១០(ដប់)ឆ្នាំ។

កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគនេះ មាន១៤មាត្រា ដែលបញ្ជាក់នូវចំណុចសំខាន់ៗ អំពីនិយមន័យ ការជំរុញនិងការការពារការវិនិយោគ ប្រព្រឹត្តិកម្មជាតិនិងប្រព្រឹត្តិកម្មជាតិអនុគ្រោះបំផុត អស្សាមិករណ៍ សំណងចំពោះការបាត់បង់ ការផ្ទេរ ឧបាទេសកម្ម វិវាទរវាងភាគីជាប់កិច្ចសន្យានិងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត វិវាទរវាងភាគីជាប់កិច្ចសន្យា ការអនុវត្តនូវវិធានផ្សេងៗទៀត ស្ថាប័នសម្របសម្រួល ភាពអាចអនុវត្តបាននៃកិច្ចព្រមព្រៀងនេះ ការពិគ្រោះយោបល់ និងការចូលជាធរមាន រយៈពេល និងការបញ្ចប់។

តាមរយៈកិច្ចព្រមព្រៀងនេះ កម្ពុជាពិតជានឹងបោះជំហានថ្មីមួយទៀតក្នុងការទាក់ទាញការវិនិយោគពីប្រទេសជាមិត្ត តាមរយៈការបង្កើនជំនឿទុកចិត្តពីសំណាក់វិនិយោគិនបេឡារុស។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស ស្តីពីការជំរុញនិងការការពារទៅវិញទៅមកនៃវិនិយោគ ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

# សេចក្តីព្រាង

# ច្បាប់

# ស្តីពី

# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ

**មាត្រា១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ ដែលបានចុះហត្ថលេខា នៅទីក្រុងមីនស្ក នៃសាធារណរដ្ឋបេឡារុស នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។/

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

អនុម័តនៅថ្ងៃទី ខែ ឆ្នាំ២០១៥

នាសម័យប្រជុំរដ្ឋសភាលើកទី នីតិកាលទី៥។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៥

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៧៥ .ស.ប្រ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ ២០១៤

# សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រីប្រចាំការ អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

# រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាពជូនឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីចុះហត្ថលេខាក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា លើកិច្ចព្រមព្រៀងស្តីពីការជំរុញ និងការការពារវិនិយោគទៅវិញទៅមក រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋបេឡារុស្ស។

អាស្រ័យហេតុនេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធពេញលេញតាមអំណាចដែលច្បាប់បានប្រគល់ជូន បានចុះហត្ថលេខាលើសិទ្ធិប្រទាននេះ។

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# កិច្ចព្រមព្រៀង
# រវាង
# រដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស
# និង
# រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# ស្តីពី
# ការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ

រដ្ឋាភិបាលនៃសាធារណៈរដ្ឋបេឡារុស និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីពេលនេះតទៅហៅថា "ភាគីជាប់កិច្ចសន្យា"

ដោយប្រាថ្នាចង់បង្កើនឱ្យកាន់តែខ្លាំង នូវកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ដើម្បីផលប្រយោជន៍ទៅវិញទៅមក របស់រដ្ឋទាំងពីរ

ដោយមានគោលបំណងដើម្បីបង្កើត និងរក្សាបាន នូវលក្ខខណ្ឌអំណោយផលសម្រាប់ការវិនិយោគ នៃអ្នកវិនិយោគរបស់ភាគីជាប់កិច្ចសន្យាម្ខាង នៅលើដែនដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត និង

ដោយមនសិការយល់ដឹងថា ការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ លើមូលដ្ឋាននៃកិច្ចព្រមព្រៀងនេះ និងបង្កើតបាននូវគំនិតផ្តួចផ្តើមធុរកិច្ចនៅក្នុងរដ្ឋទាំងពីរ

បានព្រមព្រៀងគ្នាដូចតទៅ:

## មាត្រា ១
## និយមន័យ

សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ

១- ពាក្យ *"ការវិនិយោគ"* មានរួមបញ្ចូលនូវរាល់ទ្រព្យសម្បត្តិគ្រប់ប្រភេទដែលបានវិនិយោគដោយអ្នកវិនិយោគរបស់ភាគីជាប់កិច្ចសន្យាម្ខាងនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ស្របតាមច្បាប់ និងបទប្បញ្ញត្តិនៃភាគីម្ចាស់ផ្ទះ និងជាពិសេស រួមបញ្ចូល តែមិនកំណត់ត្រឹម:

(ក) ចលនទ្រព្យ និងអចលនទ្រព្យ ក៏ដូចជាសិទ្ធិដទៃទៀតដូចជា ហ៊ីប៉ូតែក ការបញ្ចាំសិទ្ធិ សិទ្ធិលើការបញ្ចាំ និងសិទ្ធិប្រហាក់ប្រហែលផ្សេងទៀត

(ខ) ភាគហ៊ុន និងប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬទម្រង់ដទៃទៀតនៃការចូលរួមក្នុងក្រុមហ៊ុន

(គ) សិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ តាវកាលិកណាមួយដែលមានតម្លៃសេដ្ឋកិច្ច

(ឃ) កម្មសិទ្ធិបញ្ញារួមបញ្ចូលសិទ្ធិចម្លង ប្រកាសនីយបត្រតក្កកម្ម ពាណិជ្ជសញ្ញា គំរូឧស្សាហកម្ម ដែនកំណត់ភូមិសាស្ត្រ និងការកែច្នៃគំរូប្លង់ខ្នាតបច្ចេកវិទ្យា ការសម្ងាត់ពាណិជ្ជកម្ម ពាណិជ្ជនាម ជំនាញ វិជ្ជាជីវៈ និងកិត្តិនាមជំនួញ ហើយក៏មានផងដែរនូវសិទ្ធិប្រហាក់ប្រហែលដែលមានសុពលភាពកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិនៃភាគីជាប់កិច្ចសន្យាទាំងពីរ

(ង) សម្បទានផ្តល់ដោយច្បាប់ និងបទប្បញ្ញត្តិដទៃទៀត នៃភាគីជាប់កិច្ចសន្យានៅក្នុងទឹកដីដែលការវិនិយោគបានធ្វើឬតាមរយៈកិច្ចសន្យារបស់អាជ្ញាធរមានសមត្ថកិច្ចរួមបញ្ចូលសម្បទានក្នុងការស្វែងរកនិស្សារណកម្មការដាំដុះ ឬការធ្វើអាជីវកម្មធនធានធម្មជាតិ។

ការផ្លាស់ប្តូរទម្រង់ទ្រព្យណាមួយនៃទ្រព្យសម្បត្តិដែលបានវិនិយោគ ឬវិនិយោគឡើងវិញ និងមិនមានឥទ្ធិពលទៅលើចរិតនៃការវិនិយោគ ប៉ុន្តែការផ្លាស់ប្តូរនោះមិនមានបដិបញ្ញត្តិទៅនឹងច្បាប់ និងបទប្បញ្ញត្តិនៃភាគីជាប់កិច្ចសន្យាពាក់ព័ន្ធណាឡើយ។

២- ពាក្យ *"ផលពីការវិនិយោគ"* មានន័យថាចំណូលប្រមូលបានពីការវិនិយោគ និងជាពិសេស មានជាអាទិ៍ ប្រាក់ចំណេញ ភាគលាភ ការប្រាក់ សួយសារ ចំណូលមូលធន ឬការទូទាត់គ្រប់ប្រភេទណាមួយទាក់ទងទៅនឹងការវិនិយោគ

៣- ពាក្យ *"អ្នកវិនិយោគ"* មានន័យថា រូបវន្ត ឬនីតិបុគ្គលនៃភាគីជាប់កិច្ចសន្យាម្ខាងដែលបានធ្វើការវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត

(ក) ពាក្យ *"រូបវន្តបុគ្គល"* មានន័យថា រូបវន្តបុគ្គលដែលមានសញ្ជាតិនៃភាគីជាប់កិច្ចសន្យាម្ខាងណាមួយ ដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន។

(ខ) ពាក្យ *"នីតិបុគ្គល"* មានន័យចំពោះភាគីជាប់កិច្ចសន្យាម្ខាងណាមួយជានីតិបុគ្គលដែលបានបង្កើត និងចុះបញ្ជីដែលអនុលោមទៅតាមច្បាប់របស់ខ្លួន និងត្រូវបានច្បាប់ទទួលស្គាល់ថាជានីតិបុគ្គល។

៤- ពាក្យ *"ទឹកដី"* មានន័យថា ដែនគោក ដែនទឹកសាប និងដែនសមុទ្រនៃភាគីជាប់កិច្ចសន្យា និងដែនអាកាសខាងលើក៏ដូចជាតំបន់សមុទ្រនៃដែនសមុទ្រ រួមបញ្ចូលបាតសមុទ្រ និងដីក្រោមបាតសមុទ្រដែលទាំងអស់នេះភាគីជាប់កិច្ចសន្យាអនុវត្តនូវសិទ្ធិ អធិបតេយ្យ ឬយុត្តាធិការ ដោយអនុលោមទៅតាមច្បាប់ជាតិជាធរមាន និងច្បាប់អន្តរជាតិ។

## មាត្រា ២
## ការជំរុញ និងការការពារការវិនិយោគ

១- ភាគីជាប់កិច្ចសន្យានីមួយៗត្រូវលើកទឹកចិត្ត និងបង្កើតនូវលក្ខខណ្ឌអំណោយផលដល់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតដើម្បីធ្វើការវិនិយោគនៅក្នុងទឹកដីរបស់ផងខ្លួន ហើយត្រូវផ្តល់ការអនុញ្ញាតឱ្យការវិនិយោគទាំងនោះ ដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន។

២- ការវិនិយោគរបស់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងណាមួយ ត្រូវបានផ្តល់ឱ្យនូវប្រព្រឹត្តិកម្មដែលត្រឹមត្រូវ និងសមធម៌ និងទទួលបាននូវការការពារ និងសន្តិសុខយ៉ាងពេញលេញ នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត។ គ្មានភាគីជាប់កិច្ចសន្យាណាមួយ ទោះតាមរូបភាពណាក៏ដោយ អាចធ្វើឱ្យខូចប្រយោជន៍ដោយវិធានការមិនសមហេតុផល ឬរើសអើងនៅក្នុងការគ្រប់គ្រង ការថែទាំ ការប្រើប្រាស់ និងការទទួលផល ឬការរំលាយនៃការវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតឡើយ។ ភាគីជាប់កិច្ចសន្យានីមួយៗត្រូវពិនិត្យមើលនូវកាតព្វកិច្ចណាមួយដែលអាចចូលជាធរមាន ចំពោះការវិនិយោគនៃអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត។

## មាត្រា ៣
## ប្រព្រឹត្តិកម្មជាតិ និងប្រព្រឹត្តិកម្មជាតិអនុគ្រោះបំផុត

១- ភាគីជាប់កិច្ចសន្យានីមួយៗត្រូវផ្តល់ឱ្យចំពោះការវិនិយោគ និងផលពីការវិនិយោគនៃអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនូវប្រព្រឹត្តិកម្ម មិនតិចជាងអ្វីដែលខ្លួនបានផ្តល់ឱ្យការវិនិយោគ និងផលពីការវិនិយោគ នៃអ្នកវិនិយោគរបស់ខ្លួន ឬទៅដល់អ្នកវិនិយោគនៃតតីយរដ្ឋនោះឡើយ ពោលគឺភាពអនុគ្រោះមួយណាដែលប្រសើរជាងទៅតាមស្ថានភាពអ្នកវិនិយោគដែលពាក់ព័ន្ធ។

២- ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវផ្តល់ឱ្យចំពោះអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត នៅក្នុងទឹកដីរបស់ខ្លួន នូវប្រព្រឹត្តិកម្មអនុគ្រោះបំផុតមិនតិចជាងអ្វីដែលខ្លួនបានផ្តល់ឱ្យអ្នកវិនិយោគរបស់ខ្លួន ឬអ្នកវិនិយោគនៃតតីយរដ្ឋ ពោលគឺភាពអនុគ្រោះមួយណាដែលប្រសើរ និងទៅតាមស្ថានភាពរបស់អ្នកវិនិយោគដែលពាក់ព័ន្ធនឹងការគ្រប់គ្រង ការថែទាំ ការប្រើប្រាស់ ការទទួលផល ឬការចាត់ចែងនៃការវិនិយោគរបស់គេជាងអ្វីដែលបានយល់ព្រមផ្តល់។

៣- បញ្ញត្តិនៃកថាខណ្ឌទី១ និង២នៃមាត្រានេះមិនត្រូវបកស្រាយចំពោះកាតព្វកិច្ច នៃភាគីជាប់កិច្ចសន្យាម្ខាងដើម្បីផ្តល់ឱ្យចំពោះអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត និងការវិនិយោគរបស់ពួកគេនូវផលប្រយោជន៍នៃ

ប្រព្រឹត្តិកម្មណាមួយ ការអនុគ្រោះ ឬបុព្វសិទ្ធិដែលអាចមានវិសាលភាពសម្រាប់ទទួលបានរបស់ភាគីម្ចាស់ផ្ទះដោយអាស្រ័យលើ :

ក) តំបន់ពាណិជ្ជកម្មសេរី សហព័ន្ធគយ ទីផ្សាររួម សហគមន៍រូបិយវត្ថុ និងសេដ្ឋកិច្ច ឬកិច្ចព្រមព្រៀងអន្តរជាតិប្រហាក់ប្រហែលគ្នារួមបញ្ចូលទម្រង់ផ្សេងៗទៀតនៃសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់ដែលក្នុងនោះភាគីជាប់កិច្ចសន្យាម្ខាងណាមួយ គឺជាភាគី ឬដែលនឹងក្លាយជាភាគី

ខ) កិច្ចព្រមព្រៀងស្តីពីការបញ្ចៀសការយកពន្ធត្រួតគ្នា ឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតពាក់ព័ន្ធមួយផ្នែក ឬទាំងស្រុងទៅនឹងកិច្ចការសារពើពន្ធ។

## មាត្រា ៤
## អស្សាមិករណ៍

១- ការវិនិយោគនៃអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងណាមួយ ពុំត្រូវបានធ្វើជាតូបនីយកម្ម ដកហូត ឬធ្វើជាកម្មវត្ថុតាមវិធានការណ៍ណាមួយដោយផ្ទាល់ ឬដោយប្រយោលដែលមានឥទ្ធិពលសមមូលទៅនឹងការធ្វើជាតូបនីយកម្ម ឬការដកហូត (ចាប់ពីពេលនេះតទៅហៅថា "អស្សាមិករណ៍") នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតឡើយ លើកលែងតែក្នុងគោលបំណងដែលជាផលប្រយោជន៍សាធារណៈ លើមូលដ្ឋានដោយពុំមានការរើសអើង និងស្របទៅនឹងនីតិវិធីនៃច្បាប់ដោយភ្ជាប់នូវសំណងភ្លាមៗគ្រប់ចំនួន និងមានប្រសិទ្ធភាព។

២- សំណងត្រូវធ្វើដោយពុំមានការពន្យារពេលជារូបិយវត្ថុ ដែលត្រូវបានអនុវត្តសម្រាប់ការវិនិយោគ និងត្រូវមានប្រសិទ្ធភាព ទទួលយកបាន និងផ្ទេរបានដោយសេរី។ សំណងដូចនេះត្រូវមានចំនួនសមស្របទៅនឹងតម្លៃទីផ្សារដ៏ត្រឹមត្រូវនៃការវិនិយោគដែលបានធ្វើអស្សាមិករណ៍នាពេលជាបន្ទាន់មុនការធ្វើ ឬការបំរុងនឹងធ្វើអស្សាមិករណ៍ ត្រូវបានដឹងឮជាសាធារណៈ ណាមួយដែលឆាប់ជាង និងត្រូវបញ្ចូលផងដែរនូវការប្រាក់ចាប់ពីថ្ងៃនៃការធ្វើ អស្សាមិករណ៍រហូតដល់ថ្ងៃដែលបានទូទាត់ទៅតាមអត្រាដែលមិនតិចជាងអត្រាការប្រាក់ London Interbank Offered Rate (Libor) ដោយសមស្របទៅនឹងរូបិយវត្ថុដែលការវិនិយោគបានធ្វើកន្លងមក។

៣- នៅពេលដែលភាគីជាប់កិច្ចសន្យាធ្វើអស្សាមិករណ៍នូវទ្រព្យទាំងឡាយ ឬមួយផ្នែករបស់ក្រុមហ៊ុនដែលបានចុះបញ្ជីឬបង្កើតឡើងស្របទៅតាមច្បាប់ជាធរមាននៅក្នុងទឹកដីរបស់ខ្លួនដែលអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតមានការវិនិយោគរាប់បញ្ចូលភាពជាម្ចាស់នៃភាគហ៊ុន វាត្រូវតែបានធានាថាបញ្ញត្តិ នៃមាត្រានេះត្រូវអនុវត្តន៍ទៅតាមវិសាលភាពដ៏ចាំបាច់ក្នុងការធានានូវសំណងជាបន្ទាន់គ្រប់ចំនួន និងមានប្រសិទ្ធភាពចំពោះការវិនិយោគរបស់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត។

៤- អ្នកវិនិយោគដែលការវិនិយោគត្រូវបានធ្វើអស្សាមិករណ៍ មានសិទ្ធិក្នុងការពិនិត្យជាបន្ទាន់ឡើងវិញ សម្រាប់ករណីរបស់ខ្លួន និងការវាយតម្លៃលើការវិនិយោគ ដោយអនុលោមទៅតាមគោលការណ៍កំណត់នៃមាត្រានេះតាមរយៈតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតនៃភាគីជាប់កិច្ចសន្យាដែលបានធ្វើអស្សាមិករណ៍។

## មាត្រា ៥
## សំណងចំពោះការខាតបង់

១- អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាង ដែលបានធ្វើការវិនិយោគរបស់ខ្លួននៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ទទួលរងការខាតបង់ដោយសារសង្គ្រាម ឬជម្លោះប្រដាប់អាវុធផ្សេងៗ ស្ថានភាពប្រទេសជាតិប្រកាសអាសន្ន បដិវត្តន៍ ការបះបោរ ឬកុបកម្ម នៅក្នុងទឹកដីនៃភាគីជាម្ចាស់ផ្ទះ នឹងត្រូវទទួលបាននូវប្រព្រឹត្តិកម្មទាក់ទងនឹងការស្តារឡើងវិញ ការចេញសង សំណង ឬការទូទាត់ផ្សេងទៀត ដែលមានលក្ខណៈអនុគ្រោះមិនតិចជាងសំណង ដែលផ្តល់ដោយភាគីជាម្ចាស់ផ្ទះទៅឱ្យអ្នកវិនិយោគរបស់ខ្លួន ឬអ្នកវិនិយោគនៃប្រជាជាតិដែលមានភាពអនុគ្រោះបំផុត ពោលគឺណាមួយដែលមានលក្ខណៈអនុគ្រោះជាង។

២- ដោយគ្មានបុរេនិច្ឆ័យចំពោះកថាខណ្ឌទី១ នៃមាត្រានេះ អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាមួយ ដែលក្នុងស្ថានភាពណាមួយដោយយោងទៅតាមកថាខណ្ឌនេះទទួលរងការខាតបង់នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតបណ្តាលមកពី :

(ក) រឹបអូសនូវការវិនិយោគរបស់ខ្លួនទាំងអស់ ឬមួយផ្នែកដោយកម្លាំងទ័ព ឬអាជ្ញាធរនៃភាគីម្ចាស់ផ្ទះ ឬ

(ខ) ហាយនភាពនូវការវិនិយោគរបស់ខ្លួនទាំងអស់ ឬមួយផ្នែកដោយកម្លាំងទ័ព ឬអាជ្ញាធរនៃភាគីម្ចាស់ផ្ទះដែលមិនតម្រូវដោយស្ថានភាពចាំបាច់ត្រូវបានផ្តល់ឱ្យដោយភាគីម្ចាស់ផ្ទះអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួននូវការស្តារឡើងវិញ ឬសំណងដែល នៅក្នុងករណីណាក៏ដោយ ត្រូវធ្វើជាប្រញាប់គ្រប់ចំនួន និងមានប្រសិទ្ធភាព និងចំពោះសំណងត្រូវធ្វើស្របទៅតាមវាក្យខណ្ឌ ២ ដល់ ៤ នៃមាត្រាទី ៤ នៃកិច្ចព្រមព្រៀងនេះ គិតចាប់ពីថ្ងៃនៃការរឹបអូស ឬហាយនភាពរហូតដល់ថ្ងៃទូទាត់។

## មាត្រា ៦
## ការផ្ទេរ

១- ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវធានាដោយយោងទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់ជាតិតាមករណីណាមួយ ចំពោះអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ក្រោយពេលដែលបានបំពេញរួចរាល់នូវកាតព្វកិច្ចសារពើពន្ធ ឱ្យមានការផ្ទេរនូវការទូទាត់ពាក់ព័ន្ធការវិនិយោគរបស់គេ ជាពិសេស មានជាអាទិ៍:

ក) ផលពីការវិនិយោគ ដូចមានចែងក្នុងកថាខណ្ឌ ២ មាត្រា ១ នៃកិច្ចព្រមព្រៀងនេះ

ខ) មូលធន និងចំនួនបន្ថែមចាំបាច់សម្រាប់ការថែទាំ ឬការអភិវឌ្ឍន៍នៃវិនិយោគ

គ) មូលនិធិក្នុងការទូទាត់ប្រាក់កម្ចី

ឃ) ប្រាក់ចំណូលបានមកពីការលក់សរុប ឬមួយផ្នែក ឬការជម្រះបញ្ជីនៃការវិនិយោគ

ង) សំណងតាមមាត្រា ៤ និង ៥ នៃកិច្ចព្រមព្រៀងនេះ

ច) ចំណូលនៃរូបវន្តបុគ្គលទទួលបានពីបរទេសពាក់ព័ន្ធនឹងការវិនិយោគស្របតាមច្បាប់ និងបទប្បញ្ញត្តិនៃភាគីជាប់កិច្ចសន្យាដែលការវិនិយោគបានធ្វើនៅលើទឹកដីនោះ។

២- ការផ្ទេរដែលបានបញ្ជាក់ក្នុងមាត្រានេះ ត្រូវធ្វើឡើងដោយគ្មានការពន្យារពេល ដោយរូបិយវត្ថុដែលអាចប្តូរបានដោយសេរីតាមអត្រាប្តូរប្រាក់ដែលអនុវត្តន៍នៅថ្ងៃផ្ទេរដោយផ្អែកទៅតាមបទប្បញ្ញត្តិនៃការប្តូរប្រាក់ជាធរមាន នៃភាគីជាប់កិច្ចសន្យាអំពីទឹកដីដែលការផ្ទេរបានធ្វើឡើង ។

## មាត្រា ៧
## ឧបាទេសកម្ម

ប្រសិនបើភាគីជាប់កិច្ចសន្យាមួយ ឬភ្នាក់ងារដែលបានតែងតាំងរបស់ខ្លួន បានធ្វើការទូទាត់ដើម្បីជាសំណងជាការធានា ឬកិច្ចសន្យាធានារ៉ាប់រងផ្តល់ឱ្យចំពោះការវិនិយោគនៃអ្នកវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ភាគីម្ចាស់ផ្ទះត្រូវទទួលស្គាល់ការផ្ទេរនូវសិទ្ធិណាមួយ ឬសិទ្ធិលើបំណុលនៃអ្នកវិនិយោគ នោះចំពោះភាគីជាប់កិច្ចសន្យាខាងដើម ឬភ្នាក់ងារដែលបានតែងតាំងរបស់គេ ហើយសិទ្ធិនៃភាគីជាប់កិច្ចសន្យាខាងដើម ឬភ្នាក់ងារដែលបានតែងតាំងដើម្បីធ្វើកិច្ចការនោះ ដោយផ្អែកលើឧបាទេសកម្មនូវសិទ្ធិដូចនេះ និងការទាមទារដែលមានវិសាលភាពដូចអ្នកផ្តល់សិទ្ធិជាម្ចាស់ដែរ។

## មាត្រា ៨

## វិវាទរវាងភាគីជាប់កិច្ចសន្យា និងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត

១- វិវាទណាមួយកើតឡើងដោយផ្ទាល់ ពីការវិនិយោគរវាងភាគីជាប់កិច្ចសន្យាម្ខាង និងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតត្រូវដោះស្រាយដោយមិត្តភាពរវាងភាគីដែលមានវិវាទទាំងពីរ។

២- ប្រសិនបើវិវាទមិនត្រូវបានដោះស្រាយក្នុងអំឡុងពេលប្រាំមួយ (៦) ខែ គិតចាប់ពីថ្ងៃដែលមានការជូនដំណឹងជាលាយលក្ខណ៍អក្សរទេ អ្នកវិនិយោគអាចជ្រើសរើសដាក់វិវាទរបស់ខ្លួនទៅ:

(ក) តុលាការមានសមត្ថកិច្ចរបស់រដ្ឋនៃភាគីជាប់កិច្ចសន្យានៅក្នុងដែនដីដែលការវិនិយោគស្ថិតនៅ ឬ

(ខ) មជ្ឈត្តការដោយមជ្ឈមណ្ឌលដោះស្រាយវិវាទវិនិយោគអន្តរជាតិ (International Center for Settlement of Investment Disputes ហៅកាត់ថា "ICSID") ដែលត្រូវបានបង្កើតឡើង ដោយអនុលោមទៅតាមកតិកាសញ្ញាស្តីពីការដោះស្រាយវិវាទវិនិយោគរវាងរដ្ឋ និងជនជាតិនៃរដ្ឋផ្សេង ចុះហត្ថលេខានៅទីក្រុង វ៉ាស៊ីនតោន ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៦៥ ប្រសិនបើភាគីជាប់កិច្ចសន្យាដែលមានវិវាទ និងភាគីជាប់កិច្ចសន្យានៃអ្នកវិនិយោគ ជាភាគីនៃកតិកាសញ្ញាស្តីពីមជ្ឈមណ្ឌលដោះស្រាយវិវាទវិនិយោគអន្តរជាតិ (ICSID) ឬ

(គ) វិធានសម្របសម្រួលបន្ថែម ICSID (ICSID Additional Facility Rules) ប្រសិនបើភាគីជាប់កិច្ចសន្យាដែលមានវិវាទឬភាគីជាប់កិច្ចសន្យានៃអ្នកវិនិយោគមិនចាំបាច់ទាល់តែភាគីទាំងពីរជាភាគីនៃកតិកាសញ្ញា ICSID ឬ

(ឃ) វេទិកាមជ្ឈត្តការតាមរូបភាព អែតហុក ដែលត្រូវបង្កើតឡើងក្រោមវិធានមជ្ឈត្តការនៃគណៈកម្មការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (United Nations Commission on International Trade Law) ហៅកាត់ថា "UNCITRAL" ដូចដែលអាចធ្វើវិសោធនកម្ម បានដោយភាគីទាំងពីរចំពោះការវិវាទ ឬ

(ង) វេទិកាមជ្ឈត្តការតាមរូបភាព អែតហុក ណាមួយផ្សេងទៀត ដែលគូភាគីនៃវិវាទបានព្រមព្រៀងគ្នា។

៣- នៅពេលដែលអ្នកវិនិយោគបានដាក់វិវាទរបស់ខ្លួនទៅនីតិវិធីដោះស្រាយវិវាទណាមួយដូចមានចែងក្នុងកថាខណ្ឌ ២(ក)ទៅ (ង) នៃមាត្រានេះហើយ នោះការជ្រើសរើសយកនីតិវិធីនេះជាជម្រើសចុងក្រោយ។

៤- មជ្ឈត្តការដែលបានកំណត់ក្នុងមាត្រានេះ ត្រូវប្រព្រឹត្តទៅនៅប្រទេសណាមួយដែលជាភាគីនៃកតិកាសញ្ញាស្តីពីការទទួលស្គាល់ និងអនុវត្តសេចក្តីសម្រេចមជ្ឈត្តការបរទេស (កតិកាសញ្ញាក្រុងញូវយ៉ក) ដែលត្រូវបានបើកឱ្យចុះហត្ថលេខានៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៥៨។ មជ្ឈត្តការដែលមានចែងក្នុងមាត្រានេះមិនត្រូវប្រព្រឹត្តទៅនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យានេះទេ។ សម្រាប់គោលបំណងនៃការអនុវត្តមាត្រា១នៃកតិកាសញ្ញា

ក្រុងញូវយ៉ក បណ្តឹងដែលដាក់ទៅមជ្ឈត្តការតាមកថាខណ្ឌ២ (ឃ)-(ង) នៃមាត្រានេះ ត្រូវចាត់ទុកថាជាបណ្តឹងដែលកើតចេញពីទំនាក់ទំនងពាណិជ្ជកម្ម ឬប្រតិបត្តិការពាណិជ្ជកម្ម។

៥- តាមរយៈកិច្ចព្រមព្រៀងនេះ ភាគីជាប់កិច្ចសន្យានីមួយៗយល់ព្រមទទួលយកសមត្ថកិច្ចដោះស្រាយវិវាទរវាងខ្លួន និងអ្នកវិនិយោគនៃប្រទេសជាប់កិច្ចសន្យាម្ខាងទៀតរបស់មជ្ឈត្តការអន្តរជាតិដូចមានកំណត់ក្នុងកថាខណ្ឌ ២(ខ)-២(ឃ) នៃមាត្រានេះ។ ដោយហេតុនេះ មិនចាំបាច់មានការព្រមព្រៀងជាលាយលក្ខណ៍អក្សររវាង ភាគីជាប់កិច្ចសន្យាម្ខាង និងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតទេ។

៦- ដាក់ចូលវិញនៅក្នុងអំឡុងពេលដែលនីតិវិធីមជ្ឈត្តការ ឬការអនុវត្តសេចក្តីសម្រេចមជ្ឈត្តការកំពុងដំណើរការ ភាគីជាប់កិច្ចសន្យាដែលពាក់ព័ន្ធជាមួយនឹងវិវាទមិនត្រូវអះអាង អំពីអធិបតេយ្យភាព ឬអង្គហេតុដែលថាអ្នកវិនិយោគនៃប្រទេសជាប់កិច្ចសន្យាម្ខាងទៀត បានទទួលរួចហើយនូវសំណងមួយផ្នែក ឬទាំងស្រុងដោយផ្អែកលើកិច្ចសន្យាធានារ៉ាប់រងជាមធ្យោបាយការពារខ្លួននោះទេ។

៧- សេចក្តីសម្រេចមជ្ឈត្តការគឺស្ថាពរ នឹងមានអនុភាពចងចំពោះគូភាគីនៃវិវាទ។

## មាត្រា ៩
## វិវាទរវាងភាគីជាប់កិច្ចសន្យា

១- វិវាទរវាងភាគីជាប់កិច្ចសន្យាពាក់ព័ន្ធទៅនឹងការបកស្រាយ និងការអនុវត្តនៃកិច្ចព្រមព្រៀងនេះក្នុងស្ថានភាពដែលអាចធ្វើទៅបានត្រូវដោះស្រាយតាមរយៈការចរចារ។

២- ប្រសិនបើវិវាទនេះមិនអាចដោះស្រាយបានក្នុងរយៈពេលប្រាំមួយ (៦) ខែ គិតចាប់ពីថ្ងៃដែលភាគីជាប់កិច្ចសន្យាម្ខាងណាមួយបានសុំឱ្យមានការចរចា វិវាទនោះដោយមានសំណើរបស់ភាគីជាប់កិច្ចសន្យាម្ខាងណាមួយនឹងត្រូវដាក់ជូនទៅវេទិកាមជ្ឈត្តការ។

៣- វេទិកាមជ្ឈត្តការដូចនេះត្រូវបង្កើតឡើងទៅតាមករណីដោយឡែកផ្ទាល់ខ្លួននីមួយៗ តាមនីតិវិធីដូចតទៅក្នុងរយៈពេលពីរ (២) ខែ នៃការទទួលបាននូវសំណើឱ្យមានការកាត់ក្តីដោយមជ្ឈត្តការ ភាគីជាប់កិច្ចសន្យានីមួយៗត្រូវតែងតាំងសមាជិកម្នាក់នៃអង្គជំនុំជម្រះ។

សមាជិកនៃអង្គជំនុំជម្រះទាំងពីររូបជាបន្ទាប់មកត្រូវជ្រើសរើស ជនជាតិនៃរដ្ឋទី៣ ម្នាក់ដោយមានការយល់ព្រមពីភាគីជាប់កិច្ចសន្យាទាំងពីរ ដើម្បីតែងតាំងធ្វើជាប្រធាននៃអង្គ ជំនុំជម្រះ។ ប្រធានត្រូវបានតែងតាំងក្នុងរយៈពេលបួន(៤) ខែ គិតចាប់ពីថ្ងៃនៃការតែងតាំង សមាជិកទាំងពីររូប។

៤- ប្រសិនបើការតែងតាំងដ៏ចាំបាច់នេះមិនត្រូវបានធ្វើក្នុងរយៈពេលបានកំណត់បញ្ជាក់ក្នុងវាក្យខ័ណ្ឌទី៣ នៃមាត្រានេះទេនោះភាគីជាប់កិច្ចសន្យាម្ខាងណាមួយអាចក្នុងករណីពុំមានការកំណត់ផ្សេងនៅក្នុងកិច្ចព្រមព្រៀងណាមួយទៀតទេអញ្ជើញប្រធាននៃតុលាការយុត្តិធម៌អន្តរជាតិដើម្បីឱ្យធ្វើការតែងតាំងដ៏ចាំបាច់នេះ។

ប្រសិនបើប្រធានតុលាការជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ ឬត្រូវបានរារាំងដោយមិនឱ្យអនុវត្តមុខងារខាងលើ សមាជិកនៃតុលាការយុត្តិធម៌អន្តរជាតិដែលមានឋានៈបន្ទាប់ ហើយដែលមិនមែនជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ ឬ មិនត្រូវបានរារាំងដោយមិនឱ្យអនុវត្តមុខងារខាងលើ ត្រូវអញ្ជើញដើម្បីមកធ្វើការតែងតាំងតាមការចាំបាច់។

៥- វេទិការមជ្ឈត្តការត្រូវធ្វើការសម្រេចក្តីដោយបោះឆ្នោតសំឡេងភាគច្រើន។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះគឺជាសេចក្តីសម្រេចចុងក្រោយដែលភាគីទាំងពីរ ត្រូវតែទទួលអនុវត្ត។ ភាគីជាប់កិច្ចសន្យានីមួយៗត្រូវទទួលរ៉ាប់រងនូវបន្ទុកចំណាយនៃសមាជិកអង្គជំនុំជម្រះដែលខ្លួនបានតែងតាំង និងចំពោះអ្នកតំណាងរបស់ខ្លួននៅក្នុងនីតិវិធីនៃអាជ្ញាកណ្តាល។ ភាគីទាំងពីរត្រូវទទួលយកនូវចំណែកស្មើគ្នានៃការចំណាយរបស់ប្រធានតុលាការក៏ដូចជាការចំណាយផ្សេងៗ។

តុលាការអាចធ្វើការសម្រេចផ្សេងពីនេះទាក់ទងទៅនឹងការបែងចែកបន្ទុកចំណាយ ទៅគ្រប់ទិដ្ឋភាពទាំងអស់ វេទិកាមជ្ឈត្តការត្រូវធ្វើការកំណត់នៃការដោះស្រាយវិវាទដោយខ្លួនឯង។

## មាត្រា ១០
## ការអនុវត្តនូវបទប្បញ្ញត្តិផ្សេងៗទៀត

១- ប្រសិនបើបញ្ញត្តិនៃច្បាប់នៃភាគីជាប់កិច្ចសន្យាណាមួយ ឬកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ ដែលមានស្រាប់ ឬបង្កើតឡើងរវាងភាគីជាប់កិច្ចសន្យាក្នុងការបន្ថែមទៅលើកិច្ចព្រមព្រៀងនេះ មានមាតិកាជាការកំណត់ទោះបីមានកំរិតទូទៅ ឬពិសេស ផ្តល់សិទ្ធិឱ្យការវិនិយោគដែលធ្វើឡើងដោយអ្នកវិនិយោគ នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត នូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះច្រើនជាងអ្វីដែលបានផ្តល់ឱ្យដោយកិច្ចព្រមព្រៀងនេះ បញ្ញត្តិដូចនេះ សម្រាប់វិសាលភាពដែលមានភាពអនុគ្រោះច្រើនជាងដល់អ្នកវិនិយោគ ត្រូវមានឧត្តមភាពជាសំអាងពីលើកិច្ចព្រមព្រៀងនេះ។

២- ភាគីជាប់កិច្ចសន្យានីមួយៗត្រូវពិនិត្យមើលរាល់កាតព្វកិច្ចផ្សេងទៀតណាមួយដែលអាចមានចំពោះការវិនិយោគជាពិសេស នៃអ្នកវិនិយោគរបស់ភាគីជាប់កិច្ចសន្យាម្ខាងទៀត។

## មាត្រា ១១
## ស្ថាប័នសម្របសម្រួល

ក្នុងគោលបំណងអនុវត្តកិច្ចព្រមព្រៀងនេះ ភាគីជាប់កិច្ចសន្យាតែងតាំងស្ថាប័នសម្របសម្រួលៈ

សាធារណៈរដ្ឋបេឡារុស : *ក្រសួងសេដ្ឋកិច្ច*

សម្រាប់ព្រះរាជាណាចក្រកម្ពុជា : *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក)*

## មាត្រា ១២

## វិសាលភាពនៃការអនុវត្តនៃកិច្ចព្រមព្រៀងនេះ

កិច្ចព្រមព្រៀងនេះ មានវិសាលភាពសម្រាប់លើវាល់ការវិនិយោគធ្វើឡើង ដោយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងណាមួយនៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួនទោះការវិនិយោគនោះបានធ្វើឡើងនៅមុនពេល ឬក្រោយការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះក៏ដោយ ប៉ុន្តែមិនត្រូវបានយកមកអនុវត្តចំពោះវិវាទណាមួយ ពាក់ព័ន្ធការវិនិយោគដែលបានកើតមានឡើងឬការតវ៉ាណាមួយដែលបានដោះស្រាយរួច ហើយមុនការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះឡើយ។

## មាត្រា ១៣

## ការពិគ្រោះយោបល់

អ្នកតំណាងនៃភាគីជាប់កិច្ចសន្យាក្នុងករណីចាំបាច់ ត្រូវរៀបចំឱ្យមានការពិគ្រោះយោបល់ស្តីពីបញ្ហាណាមួយដែលប៉ះពាល់ដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ។ ការពិគ្រោះយោបល់ទាំងនោះត្រូវធ្វើឡើងតាមសំណើនៃភាគីជាប់កិច្ចសន្យាមួយ នាទីកន្លែង និងពេលវេលាដែលបានយល់ព្រមតាមរយៈផ្លូវទូត។

## មាត្រា ១៤

## ការចូលជាធរមាន រយៈពេល និងការបញ្ចប់

១- ភាគីជាប់កិច្ចសន្យាត្រូវជូនដំណឹងទៅវិញទៅមកជាលាយលក្ខណ៍អក្សរនៅពេលដែលតម្រូវការដោយរដ្ឋធម្មនុញ្ញសម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងបានបំពេញរួចរាល់ហើយ។ កិច្ចព្រមព្រៀងត្រូវចូលជាធរមាននៅក្នុងរយៈពេល សាមសិប (៣០) ថ្ងៃ បន្ទាប់ពីថ្ងៃដែលទទួលបាននូវការជូនដំណឹងចុងក្រោយ ។

២- កិច្ចព្រមព្រៀងនេះ អាចត្រូវបានធ្វើវិសោធនកម្ម ដោយកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងភាគីជាប់កិច្ចសន្យា។ រាល់ការធ្វើវិសោធនកម្មត្រូវចូលជាធរមានទៅតាមនីតិវិធីដែលតម្រូវសម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះដែរ។

៣- កិច្ចព្រមព្រៀងនេះមានសុពលភាពរយៈពេល ដប់ (១០) ឆ្នាំ និងត្រូវបន្តមានសុពលភាពតាមរយៈពេលដូចគ្នារហូតមានភាគីជាប់កិច្ចសន្យាម្ខាងណាមួយបានជូនដំណឹងទៅម្ខាងទៀតជាលាយលក្ខណ៍អក្សរក្នុងអំឡុងពេលដប់ពីរ (១២) ខែ នូវបំណងរបស់ខ្លួនថាមិនបន្តសុពលភាពនៃកិច្ចព្រមព្រៀង។ កិច្ចព្រមព្រៀងត្រូវបានចាត់ទុកថាបញ្ចប់ក្រោយរយៈពេលដប់ពីរ (១២) ខែ គិតចាប់ពីថ្ងៃដែលភាគីជាប់កិច្ចសន្យាម្ខាងទៀតបានទទួលនូវការជូនដំណឹងនេះ។

៤- ភាគីជាប់កិច្ចសន្យាម្ខាងណាមួយអាចបញ្ចប់កិច្ចព្រមព្រៀងនេះ តាមមធ្យោបាយដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីជាប់កិច្ចសន្យាម្ខាងទៀតតាមរយៈផ្លូវទូត។ កិច្ចព្រមព្រៀងត្រូវបានចាត់ទុកថាបញ្ចប់ក្រោយរយៈពេលដប់ពីរ (១២) ខែ គិតចាប់ពីថ្ងៃដែលភាគីជាប់កិច្ចសន្យាម្ខាងទៀតបានទទួលនូវការជូនដំណឹងនេះ។

៥- ចំពោះការវិនិយោគទាំងឡាយណាដែលបានធ្វើមុនថ្ងៃបញ្ចប់កិច្ចព្រមព្រៀងនេះ បញ្ញត្តិនៃមាត្រា ១ ដល់ ១៣ នឹងបន្តនៅមានសុពលភាពសម្រាប់រយៈពេលបន្ត ដប់ (១០)ឆ្នាំ ទៀតគិតពីថ្ងៃបញ្ចប់កិច្ចព្រមព្រៀងនេះ។

ដើម្បីជាសាក្សីនៃកិច្ចព្រមព្រៀងនេះ អ្នកតំណាងស្របច្បាប់ដែលរដ្ឋាភិបាលរៀងខ្លួន បានប្រគល់អំណាចត្រឹមត្រូវមានសិទ្ធិគ្រប់គ្រាន់ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

ធ្វើនៅទីក្រុង មីនស្គ នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ ជាភាសាខ្មែរ ភាសារុស្ស៊ី និងភាសាអង់គ្លេស ដោយអត្ថបទទាំងអស់មានតំលៃស្មើគ្នាតាមផ្លូវច្បាប់។ ក្នុងករណីមានការបកស្រាយខ្វែងគ្នា អត្ថបទជាភាសាអង់គ្លេសនឹងត្រូវយកជាគោល។

តំណាងរដ្ឋាភិបាល
នៃព្រះរាជាណាចក្រកម្ពុជា

តំណាងរដ្ឋាភិបាល
នៃសាធារណរដ្ឋបេឡារុស

**AGREEMENT**
**BETWEEN**
**THE GOVERNMENT OF THE KINGDOM OF CAMBODIA AND**
**THE GOVERNMENT OF THE REPUBLIC OF BELARUS**
**ON THE PROMOTION AND RECIPROCAL PROTECTION OF INVESTMENTS**

The Government of the Kingdom of Cambodia and the Government of the Republic of Belarus, hereinafter referred to as the "Contracting Parties",

DESIRING to intensify economic cooperation to the mutual benefit of both States,

INTENDING to create and maintain favourable conditions for investments of investors of one Contracting Party in the territory of the other Contracting Party, and

CONSCIOUS that the promotion and reciprocal protection of investments, on the basis of the present Agreement, will stimulate the business initiatives in the both States,

HAVE AGREED AS FOLLOWS:

**ARTICLE 1**
**DEFINITIONS**

For the purposes of this Agreement:

1. The term "investment" shall comprise every kind of asset invested by an investor of one Contracting Party in the territory of the other Contracting Party in accordance with the laws and regulations of the latter and shall include, in particular, though not exclusively:

a) movable and immovable property as well as any other property rights such as mortgages, liens, pledges, and similar rights;

b) shares, stocks and debentures of companies or any other form of participation in a company;

c) claims to money or to any performance having an economic value;

d) intellectual property rights, including copyrights, patents, trademarks, industrial designs, geographical indications and technical processes, trade secrets, business names, know-how and goodwill, as well as other similar rights validated by the laws and regulations of both Contracting Parties;

e) concessions conferred by the laws and regulations of the Contracting Party in the territory of which the investments were made or under a contract by a competent authority, including concessions to search for, extract, cultivate or exploit natural resources.

Any alteration of the form in which assets are invested or reinvested shall not affect their character as investment provided that such alteration does not contradict the laws and regulations of the relevant Contracting Party.

2. The term "returns" shall mean amounts yielded by an investment and in particular, though not exclusively, includes profits, dividends, interest, royalties, capital gains, or any payments in kind related to an investments.

3. The term "investor" shall mean any natural or legal person of one of the Contracting Parties who invests in the territory of the other Contracting Party:

a) the term "natural person" shall mean any natural person having the nationality of either Contracting Party in accordance with its laws and regulations;

b) the term "legal person" shall mean with respect to either Contracting Party any legal entity incorporated or constituted in accordance with, and recognized as legal person by its laws.

4. The term "territory" means the land territory, internal waters and territorial sea of the Contracting Party and the airspace above them, as well as the maritime zones beyond the territorial sea, including the seabed and subsoil, over which that Contracting Party exercises sovereign rights or jurisdiction in accordance with its national laws in force and international law.

## ARTICLE 2
## PROMOTION AND PROTECTION OF INVESTMENTS

1. Each Contracting Party shall encourage and create favourable conditions for investors of the other Contracting Party to make investments in its territory and shall admit such investments, in accordance with its laws and regulations.

2. Investments of investors of either Contracting Party shall at all times be accorded fair and equitable treatment and shall enjoy full protection and security in the territory of the other Contracting Party. Neither Contracting Party shall in any way impair by unreasonable or discriminatory measures the management, maintenance, use, enjoyment or disposal of investments in its territory of investors of the other Contracting Party. Each Contracting Party shall observe any obligation it may have entered into with regard to investments of investors of the other Contracting Party.

## ARTICLE 3
## NATIONAL TREATMENT AND MOST-FAVOURED-NATION TREATMENT

1. Each Contracting Party shall in its territory accord to investments and returns of investors of the other Contracting Party treatment not less favourable than that accorded to investments and returns of its own investors or to investments or returns of investors of any third state, whichever is more favourable according to the investors concerned.

2. Each Contracting Party shall in its territory accord to investors of the other Contracting Party, as regards management, maintenance, use, enjoyment or disposal of their investment, treatment not less favourable than that accorded to its own investors or to investors of any third State, whichever is more favourable according to the investors concerned.

3. The provisions of paragraph 1 and 2 of this Article shall not be construed so as to oblige one Contracting Party to extend to the investors of the other Contracting Party and to their investments the benefit of any treatment, preference or privilege which may be extended by the former Contracting Party by virtue of:

a) free trade area, customs union, common market, economic and monetary union or similar international agreements including other forms of regional economic cooperation to which either of the Contracting Party is or may become a party;

b) agreement for the avoidance of double taxation or other international agreement relating wholly or mainly to taxation.

## ARTICLE 4
## EXPROPRIATION

1. Investments of investors of either Contracting Party shall not be nationalized, expropriated or subjected to any other measures, direct or indirect, having an effect equivalent to nationalization or expropriation (hereinafter referred to as "expropriation") in the territory of the other Contracting Party except for a purpose which is in the public interest, on a non-discriminatory basis, in accordance with due process of law, and against prompt, adequate and effective compensation.

2. The compensation shall be made without delay in the currency in which investment has been made, shall be effectively realizable and freely transferable.

Such compensation shall amount to the fair market value of the expropriated investments at the time immediately before expropriation or impending expropriation became public knowledge, whichever is the earlier, and shall include interest from the date of expropriation until the date of payment at a rate, which shall be not less than the London Interbank Offered Rate (LIBOR) in conformity with the currency in which investment has been made.

3. Where a Contracting Party expropriates the assets or a part thereof of a company, which has been incorporated or constituted in accordance with the law in force in its territory, in which investors of the other Contracting Party have an investment, including through the ownership of shares, it shall ensure that the provisions of this Article are applied to the extent necessary to guarantee prompt, adequate and effective compensation in respect of their investment to such investors of the other Contracting Party.

4. The investor whose investments are expropriated shall have the right to prompt review of its case and of valuation of its investments in accordance with the principles set out in this Article, by a judicial or other competent authority of the Contracting Party making the expropriation.

## ARTICLE 5
## COMPENSATION FOR LOSSES

1. Investors of one Contracting Party whose investments in the territory of the other Contracting Party suffer losses owing to war or other armed conflict, a state of national emergency, revolt, insurrection or riot in the territory of the latter Contracting Party, shall be accorded by the latter Contracting Party, as regards restitution, indemnification, compensation or other settlement, a treatment no less favourable than the one accorded by the latter Contracting Party to its own investors or investors of the most favoured nation, whichever, according to the investor, is the more favourable.

2. Without prejudice to paragraph 1 of this Article, investors of one Contracting Party who, in any of the situations referred to in that paragraph, suffer losses in the territory of the other Contracting Party resulting from:

(a) requisitioning of its investment or a part thereof by the latter's armed forces or authorities; or

(b) destruction of its investment or a part thereof by the latter's armed forces or authorities, which was not required by the necessity of the situation,

shall be accorded by the latter Contracting Party in accordance with its laws and regulations restitution or compensation which in either case shall be prompt, adequate and effective and, with respect to compensation, shall be made in accordance with paragraphs 2 to4 of Article 4 of the present Agreement from the date of requisitioning or destruction until the date of actual payment.

**ARTICLE 6**
**TRANSFERS**

1. Each Contracting Party, taking in to account the national laws and regulations, shallat any case guarantee to the investors of the other Contracting Party, after they have fulfilled all their fiscal obligations, the free transfer of payments relating to their investments, particularly, though not exclusively:

a) returns as defined in paragraph 2, Article 1 of this Agreement;

b) capital and additional amounts necessary for the maintenance or development of the investment;

c) funds in repayment of loans;

d) proceeds of the total or partial sale or liquidation of the investment;

e) compensation under Articles 4 and 5 of this Agreement;

f) earnings of natural persons engaged from abroad in connection with an investments subject to the laws and regulations of the Contracting Party, in which territory the investments have been made.

2. The transfers mentioned in this Article shall be made without delay in a freely convertible currency at the rate of exchange applicable on the date of transfer pursuant to the exchange regulations in force of the Contracting Party from which territory the transfer is made.

**ARTICLE 7**
**SUBROGATION**

If a Contracting Party or its designated agency makes a payment under an indemnity, guarantee or contract of insurance given in respect of an investment of an investor in the territory of the other Contracting Party, the latter Contracting Party shall recognise the assignment of any right or claim of such an investor to the former Contracting Party or its designated agency, and the right of the former Contracting Party or its designated agency to exercise by virtue of subrogation any such right and claim to the same extent as its predecessor in title.

**ARTICLE 8**
**DISPUTES BETWEEN A CONTRACTING PARTY**
**AND AN INVESTOR OF THE OTHER CONTRACTING PARTY**

1. Any dispute arising directly from an investment between one Contracting Party and an investor of the other Contracting Party should be settled amicably between the two parties to the dispute.

2. If the dispute has not been settled within six (6) months from the date on which it was notified in writing, the dispute may, at the choice of the investor, be submitted to:

(a) the competent courts of the State of the Contracting Party inthe territory of which the investment is made; or

(b) arbitration by the International Center for Settlement of Investment Disputes (ICSID), established pursuant to the Convention on the Settlement of Investment Disputes between States and Nationals of other States, opened for signature at Washington on 18 March 1965, provided that both the disputing Contracting Party and the Contracting Party of the investor are parties to the ICSID Convention; or

(c) the ICSID Additional Facility Rules, provided that either the disputing Contracting Party or the Contracting Party of the investor, but not both, is a party to the ICSID Convention;or

(d) an ad hoc arbitration tribunal to be established under the Arbitration Rules of the United Nations Commission on International Trade Law (UNCITRAL), as may be amended by the two parties to the dispute; or

(e) any other ad hoc arbitration tribunal agreed upon by the parties to the dispute.

3. Once the investor has submitted the dispute to any settlement procedure state in paragraph 2(a) to (e) of this Article, the choice of the procedure is final.

4. Any arbitration under this Article shall be held in a state that is a party to the Convention on the Recognition and Enforcement of Foreign Arbitral Awards (New York Convention), opened for signature at New York on 10 June 1958. No arbitration under this Article shall be held in the territories of the Contracting Parties. Claims submitted to arbitration under paragraph 2(d)-(e) of this Article shall be considered to arise out of a commercial relationship or transaction for the purposes of Article 1 of the New York Convention.

5. Each Contracting Party hereby gives its consent to the submission of a dispute between it and an investor of the other Contracting Party to international arbitration in accordance with the provisions of paragraphs 2(b)-2(d) of this Article. No further written agreement between a Contracting Party and an investor of the other Contracting Party is thus needed.

6. During the arbitration proceedings or the enforcement of the award, the Contracting Party involved in the dispute shall not assert, as a defense, its sovereignty or the fact that the investor of the other Contracting Party has received compensation under an insurance contract in respect of all or a part of the losses.

7. The award shall be final and binding on the parties to the dispute.

## ARTICLE 9
## DISPUTES BETWEEN THE CONTRACTING PARTIES

1. Disputes between the Contracting Parties concerning the interpretation and application of this Agreement shall, as far as possible, be settled through negotiations.

2. If the dispute cannot thus be settled within six (6) months following the date on which eitherContracting Party requested such negotiations, it shall at the request of either Contracting Party be submitted to an Arbitral Tribunal.

3. Such an Arbitral Tribunal shall be constituted for each individual case in the following

way. Within two (2) months of the receipt of the request for arbitration, each Contracting Party shall appoint one member of the Tribunal. Those two members shall then select a national of a third State who on approval by the two Contracting Parties shall be appointed Chairman of the Tribunal. The Chairman shall be appointed within four (4) months from the date of appointment of the other two members.

4. If the necessary appointments have not been made within the periods specified in paragraph 3 of this Article, either Contracting Party may, in the absence of any other agreement, invite the President of the International Court of Justice to make the necessary appointments. If the President is a national of either Contracting Party or is otherwise prevented from discharging the said function, the Member of the International Court of Justice next in seniority who is not a national of either Contracting Party or is not otherwise prevented from discharging the said function, shall be invited to make the necessary appointments.

5. The Arbitral Tribunal shall reach its decision by a majority of votes. The decisions of the Tribunal shall be final and binding on both Contracting Parties. Each Contracting Party shall bear the costs of the member appointed by that Contracting Party and of its representation in the arbitral proceedings. Both Contracting Parties shall assume an equal share of the costs of the Chairman, as well as any other costs. The Tribunal may make a different decision regarding the sharing of the costs. In all other respects, the Arbitral Tribunal shall determine its own rules of procedure.

## ARTICLE 10
## APPLICATION OF OTHER RULES

1. If the provisions of law of either Contracting Party or obligations under international law, existing at present or established hereafter between the Contracting Parties in addition to this Agreement, contain a regulation, whether general or specific, entitling investments made by investors of the other Contracting Party to a treatment more favourable than is provided by this Agreement, such provisions shall, to the extent that they are more favourable to the investor, prevail over this Agreement.

2. Each Contracting Party shall observe any other obligation it may have with regard to a specific investment of an investor of the other Contracting Party.

## ARTICLE 11
## COORDINATING INSTITUTIONS

For the purposes of implementation of the present Agreement the Contracting Parties appoint coordinating institutions:

from the Kingdom of Cambodia–the Council for the Development of Cambodia
from the Republic of Belarus–the Ministry of Economy;

## ARTICLE 12
## APPLICABILITY OF THIS AGREEMENT

This Agreement shall apply to all investments made by investors of either Contracting Party in the territory of the other Contracting Party in accordance with its laws and regulations, whether made before or after the entry into force of this Agreement, but shall not apply to any dispute concerning an investment that arose or any claim that was settled before its entry into force.

**ARTICLE 13**
**CONSULTATIONS**

Representatives of the Contracting Parties shall, whenever necessary, hold consultations on any matter affecting the implementation of this Agreement. These consultations shall be held on the proposal of one of the Contracting Parties at a place and a time to be agreed upon through diplomatic channels.

**ARTICLE 14**
**ENTRY INTO FORCE, DURATION AND TERMINATION**

1. The Contracting Parties shall notify each other in writing when their constitutional requirements for the entry into force of this Agreement have been fulfilled. The Agreement shall enter into force on the thirtieth (30) day following the date of receipt of the last notification.

2. This Agreement may be amended by written agreement between the Contracting Parties. Any amendment shall enter into force under the same procedure required for entering into force of the present Agreement.

3. This Agreement shall remain in force for a period of ten (10) years and shall thereafter remain in force on the same terms until either Contracting Party notifies the other in writing of its intention not to extend the validity of the Agreement in twelve (12) months. The Agreement shall be considered terminated after twelve (12) months from the date when the other Contracting Party has received such notification.

4. Either Contracting Party may terminate this Agreement by means of written notification to the other Contracting Party through diplomatic channels. The Agreement shall be considered terminated after twelve (12) months from the date when the other Contracting Party has received such notification.

5. In respect of investments made prior to the date of termination of this Agreement, the provisions of Article 1 to Article 13 shall remain in force for a further period of ten (10) years from the date of termination of this Agreement.

IN WITNESS WHEREOF, the undersigned representatives, duly authorized thereto, have signed this Agreement.

DONE in duplicate at Minsk on 23rd April 2014 in Khmer, Russian and English languages, all texts being equally authentic. In case of divergence, the English text shall prevail.

| | |
|---|---|
| **FOR THE GOVERNMENT OF THE KINGDOM OF CAMBODIA** | **FOR THE GOVERNMENT OF THE REPUBLIC OF BELARUS** |
| [signature] | [signature] |